LONG BEACH
HEALTH & HUMAN SERVICES

# ពិធីការដំរុំពេលថ្ងៃ: ឧបសម្ព័ន្ធ N

**ការកែប្រែថ្មីៗ:**

- 10/23/20 – ការប្រើប្រាស់ឧបករណ៍លេងតាមទីធ្លាកំសាន្តខាងក្រៅ ត្រូវបានអនុញ្ញាតិ តាមការសំរេចចិត្តរបស់ប្រតិបត្តិករ។ ឧបករណ៍ទីធ្លាកំសាន្តខាងក្នុងផ្ទះ នៅតែត្រូវតែបិទ។

ពិធីការនេះនឹងត្រូវបានបំពេញដោយជំរុំពេលថ្ងៃ។ បន្ថែមលើល័ក្ខខ័ណ្ឌនានា ដែលបានដាក់លើសកម្មភាពជាក់លាក់ទាំងនេះ ដោយមន្ត្រីសុខភាពសាធារណៈរដ្ឋ, កន្លែងទាំងនោះ ក៏ត្រូវគោរពតាមពិធីការបោះជំរុំពេលថ្ងៃ ទាំងនេះផងដែរ។ ពិធីសារនេះត្រូវតែអនុវត្ត និងបិទផ្សាយនៅនឹងកន្លែង ឬអាចអោយមាន/រកបាន តាមការស្នើសុំពីបុគ្គលិកទីក្រុង។

គោលការណ៍ណែនាំទាំងនេះស៊ីសង្វាក់ ឬត្រូវនឹងគោលការណ៍ណែនាំបណ្តោះអាសន្ន របស់មជ្ឈមណ្ឌលត្រួតពិនិត្យ និងបង្ការជំងឺ (CDC) សម្រាប់ការបើកឡើងវិញនូវកម្មវិធីថែទាំកុមារ, សមាគមជំរុំអាមេរិក (ACA) និងនាយកដ្ឋានសុខភាពសាធារណៈខោនធីឡូសអានចែលឡេស (សុខភាពសាធារណៈ), ដែលត្រូវផ្លាស់ប្តូរផ្អែកលើ ទិសដៅក្នុងមូលដ្ឋាន, រដ្ឋ និងសហព័ន្ធដើម្បីដំណើរការ។ ផងដែរ សកម្មភាព និងកម្មវិធីទាំងឡាយ ក៏ត្រូវតែប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំ របស់សហព័ន្ធ ដូចជាច្បាប់ជនពិការអាមេរិកាំង (ADA)។ កម្មវិធីទាំងឡាយ ដែលប្រតិបត្តិការក្រោមកិច្ចព្រមព្រៀងប្រើប្រាស់រួម និងកិច្ចព្រមព្រៀងក្នុងកិច្ចសន្យាផ្សេងទៀត  នឹងត្រូវការ សម្របសម្រួល ជាមួយអង្គភាពដែលជាដៃគូដើម្បីដោះស្រាយ ការរឹតបន្តឹង និងតម្រូវការបន្ថែម សម្រាប់ប្រតិបត្តិការកម្មវិធី។ ការរឹតបន្តឹងដូចខាងក្រោម, ពិធីការអនាម័យ និងគោលការណ៍ណែនាំត្រួតពិនិត្យ ត្រូវបានទាមទារ ដើម្បីធានាសុខភាព និង សុវត្ថិភាពរបស់បុគ្គលិក, អ្នកបោះជំរុំ និងអ្នកទស្សនា នៅពេលបង្កើតផែនការបើកដំណើរការឡើងវិញ។

សូមកត់សំគាល់៖ ឯកសារនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលព័ត៌មាន និងធនធាននានាបន្ថែមទៀត អាចរកបាន ដូច្នេះត្រូវប្រាកដថា នឹងពិនិត្យមើលលើគេហទំព័រឡងបិច COVID-19  នៅឯ www.longbeach.gov/covid19 ជាប្រចាំ ដើម្បីទទួលបានព័ត៌មានថ្មីៗ ចំពោះឯកសារនេះ។

- ❑ មានអាងហែលទឹកនៅជំរុំពេលថ្ងៃ ត្រូវតែគោរពតាម ពិធីការសំរាប់អាងហែលទឹកសាធារណៈ (ឧបសម្ព័ន្ធ K)។
- ❑ ទីធ្លាការិយាល័យនានា សំរាប់ជំរុំពេលថ្ងៃ ត្រូវតែគោរពតាម ពិធីការការិយាល័យការងារ (ឧបសម្ព័ន្ធទី G)។

បញ្ជីផ្ទៀងផ្ទាត់នេះ រួមមាននូវ៖

(1) គោលនយោបាយនានា និងការអនុវត្តនៅកន្លែងធ្វើការ ដើម្បីការពារសុខភាពនិយោជិក

(2) វិធានការណ៍នានា ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា

(3) វិធានការណ៍នានា ដើម្បីធានាការគ្រប់គ្រងការឆ្លង

(4) ការប្រាស្រ័យទាក់ទងជាមួយនិយោជិក និងសាធារណៈជន

(5) វិធានការណ៍នានា ដើម្បីធានាបាននូវការទទួលបាននូវសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

ផ្នែកសំខាន់ៗទាំងប្រាំនេះ ត្រូវតែបានដោះស្រាយខណៈពេលដែលកន្លែងរបស់អ្នក អភិវឌ្ឍនូវពិធីការបើកឡើងវិញនោះ។

**អាជីវកម្មទាំងអស់ ដែលបានស្ថិតនៅក្នុងវិធានការណ៍ណែនាំខាងក្រោមនេះ ត្រូវត្រៀមជាស្រេច ដើម្បីពន្យល់ ថាតើហេតុអ្វីបានជាវិធានការណ៍ណាមួយ ដែលមិនបានត្រូវអនុវត្ត គឺមិនអាចអនុវត្តបានចំពោះអាជីវកម្ម។**

ឈ្មោះជំរុំពេលថ្ងៃ: ______________________________

អាស័យដ្ឋានកន្លែង: ______________________________

## A. គោលនយោបាយកន្លែងធ្វើការ និងវិធានការណ៍នានា ដើម្បីការពារសុខភាពនិយោជិក (គួសទាំងអស់ដែលអនុវត្តចំពោះទីកន្លែង):

- ❑ មនុស្សគ្រប់រូបដែលអាចបំពេញភារៈកិច្ចការងាររបស់ពួកគេពីផ្ទះ ត្រូវបានគេណែនាំអោយធ្វើដូច្នេះ។
- ❑ បុគ្គលិកដែលងាយរងគ្រោះ (អ្នកដែលមានអាយុលើសពី ៦៥ ឆ្នាំ, អ្នកដែលមានលក្ខ័ណ្ឌសុខភាពរ៉ាំរ៉ៃ) ត្រូវបានចាត់តាំងអោយធ្វើការដែលអាចធ្វើបានពីផ្ទះ នៅពេលណាដែលអាចធ្វើទៅបាន។
- ❑ ដំណើរការការងារត្រូវបានកំណត់ឡើងវិញតាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីបង្កើនឱកាសសម្រាប់និយោជិកធ្វើការពីផ្ទះ។ ពិចារណាផ្តល់ជូនកម្មករ, គ្រូ, កម្មសិក្សាការី, និងបុគ្គលិកស្ម័គ្រចិត្តណា ដែលស្នើសុំជម្រើសភារៈកិច្ច ដែលបានកែប្រែ ដែលកាត់បន្ថយនូវទំនាក់ទំនងរបស់ពួកគេ ជាមួយភ្ញៀវ និងនិយោជិកផ្សេងទៀត (ឧទាហរណ៍, ការគ្រប់គ្រងសារពើភ័ណ្ឌ ជាជាងធ្វើការជាអ្នកគិតលុយ ឬគ្រប់គ្រងតម្រូវការរដ្ឋបាល តាមរយៈការងារតេលេ)
- ❑ កាលវិភាគឆ្លាស់គ្នា, បន្តបន្ទាប់គ្នា ឬប្តូរវេន ត្រូវបានបង្កើតឡើង ដើម្បីពង្រីកគំលាតឆ្ងាយរាងកាយពីគ្នា។
- ❑ និយោជិកទាំងអស់ (រាប់បញ្ចូលទាំងបុគ្គលិកដែលទទួលបានប្រាក់ឈ្នួល, និងអ្នកស្ម័គ្រចិត្ត; ដែលត្រូវបានសំដៅជា សមូហភាព ថាជា "និយោជិក") ត្រូវបានគេប្រាប់ថា មិនឱ្យមកធ្វើការប្រសិនបើឈឺ ឬប្រសិនបើពួកគេត្រូវបានប៉ះពាល់ នឹងអ្នកដែលមានជំងឺ COVID-19។ និយោជិក យល់ថាត្រូវធ្វើតាមបទបញ្ជារបស់មន្ត្រីសុខភាពទីក្រុងឡុងប៊ីឆ សំរាប់ការដាក់ខ្លួនអោយនៅឯកោ និង ការដាក់ខ្លួនអោយនៅឃ្លាតឆ្ងាយពីអ្នកដ៏ទៃ, ប្រសិនបើអាចធ្វើទៅបាន។ គោលនយោបាយ ឈប់សម្រាកនៅកន្លែងធ្វើការត្រូវ បាន ពិនិត្យ និងកែប្រែ ដើម្បីធានាថាអ្នកធ្វើការមិនត្រូវបានពិន័យ នៅពេលពួកគេស្នាក់ នៅផ្ទះដោយសារជំងឺនោះឡើយ។
    - ○ ព័ត៌មានអំពីអត្ថប្រយោជន៍ នៃការឈប់សម្រាកដែលឧបត្ថម្ភដោយនិយោជក ឬរដ្ឋាភិបាល ដែលនយោជិកអាចមានសិទ្ធិទទួលបាន ដែលនឹងធ្វើឱ្យវាកាន់តែមានភាពងាយស្រួលខាងផ្នែកហិរញ្ញវត្ថុ ក្នុងពេលស្នាក់នៅផ្ទះ។ សូមមើលព័ត៌មានបន្ថែម ស្តីពីកម្មវិធីរបស់រដ្ឋាភិបាល ដែលគាំទ្រការឈប់សម្រាកឈឺ និង សំណងរបស់កម្មករ សម្រាប់ជំងឺ COVID19, រួមមានសិទ្ធិឈប់សម្រាកឈឺរបស់និយោជិក ក្រោមច្បាប់ឆ្លើយតប ជំងឺខ្សូណាវីរ៉ុស គ្រួសារជាចំបង និងសិទ្ធិរបស់និយោជិក ចំពោះអត្ថប្រយោជន៍សំណងរបស់កម្មករ និងការសន្មត ថាការងារ ដែលជាប់ទាក់ទងនឹងជំងឺ COVID-19 ដោយអនុលោមតាមបទបញ្ជាប្រតិបត្តិរបស់អភិបាលរដ្ឋ លេខ N-62-20។
- ❑ នៅពេលទទួលបានដំណឹងថានិយោជិកម្នាក់ ឬច្រើននាក់ ធ្វើតេស្តិ៍វិជ្ជមាន, ឬមានរោគសញ្ញាស្របគ្នាទៅនឹងជំងឺ COVID-19 (ករណី), និយោជកត្រូវមានផែនការ ឬពិធីសារដើម្បីអោយករណីដាក់ខ្លួនគេអោយនៅឯកោនៅផ្ទះ ហើយតម្រូវអោយមានការដាក់អោយនៅឃ្លាតដាច់ឆ្ងាយពីគេ ខ្លួនឯងភ្លាមៗចំពោះ ឬនៃនិយោជិកទាំងអស់ ដែលមានការប្រឈមនៅនឹងកន្លែង ធ្វើការ ទៅនឹងករណី។ ផែនការរបស់និយោជក គួរតែពិចារណាលើពិធីការសម្រាប់និយោជិកដែលបានដាក់ខ្លួនអោយនៅ ឃ្លាតដាច់ឆ្ងាយពី គេទាំងអស់មានលទ្ធភាពធ្វើតេស្ត ឬត្រូវបានធ្វើតេស្ត សំរាប់ជំងឺ COVID-19 ដើម្បីកំណត់ថា តើមាន ការប្រឈមនៅកន្លែងធ្វើ ការបន្ថែមទៀត, ដែលអាចតម្រូវឱ្យមានវិធានការណ៍ត្រួតពិនិត្យជំងឺ COVID-19 បន្ថែម។

- ❑ ការត្រួតពិនិត្យរោគសញ្ញា ត្រូវបានធ្វើឡើងមុនពេលនិយោជិកអាចចូលធ្វើការ។ ការត្រួតពិនិត្យត្រូវ តែរាប់បញ្ចូលទាំងការសួរនាំ ឬឆែកឆេរទាក់ទងទៅនឹងការក្អក, ដង្ហើមខ្លី/ដង្ហក់ ឬគ្រុនក្តៅ និងរោគសញ្ញាផ្សេងទៀត ដែលបុគ្គលិកអាចនឹងកំពុងជួបប្រទះ។ ការត្រួតពិនិត្យទាំងនេះ អាចត្រូវបានធ្វើឡើងពីចម្ងាយ ឬដោយផ្ទាល់ នៅពេលមកដល់របស់និយោជិក។ ការត្រួតពិនិត្យសីតុណ្ហភាព គួរតែត្រូវបានធ្វើនៅកន្លែងធ្វើការ, ប្រសិនបើអាចធ្វើទៅបាន។
- ❑ និយោជិកទាំងអស់ដែលមានទំនាក់ទំនងជាមួយសាធារណៈជន ឬនិយោជិកផ្សេងទៀត ក្នុងកំឡុងវេនរបស់ពួកគេ ត្រូវបានផ្តល់ជូន, ដោយឥតគិតថ្លៃ, ចំពោះគម្របមុខ។ គម្របមុខ គឺត្រូវពាក់ដោយនិយោជិកគ្រប់ពេលវេលាទាំងអស់ នៅពេលថ្ងៃធ្វើការ នៅពេលមានការប៉ះពាល់ ឬទំនងជាទាក់ទងជាមួយអ្នកដទៃ, និយោជិកមិនចាំបាច់ពាក់គម្របមុខក្រណាត់នោះទេ នៅពេលនិយោជិកនៅម្នាក់ឯង ក្នុងការិយាល័យឯកជន ឬគូបដែលមានជញ្ជាំង។
- ❑ និយោជិកត្រូវបានណែនាំ អោយលាងសំអាតគម្របមុខរបស់ពួកគេ ជារៀងរាល់ថ្ងៃ។
- ❑ ផងដែរ និយោជិកត្រូវបានគេផ្តល់ស្រោមដៃអោយ សម្រាប់ភារៈកិច្ចដែលតម្រូវអោយពួកគេធ្វើការជាមួយនឹង ផ្ទៃដែលប៉ះពាល់ជាញឹកញាប់ ឬសម្រាប់ប្រើក្នុងកំឡុងពេលពិនិត្យនូវរោគសញ្ញា។
- ❑ ពិចារណាអំពីការប្រើប្រាស់នូវកញ្ចក់របាំងបែងចែកប្លាស្ទិច នៅក្នុងតំបន់ដែលនិយោជិកត្រូវធ្វើអន្តរៈកម្ម ជាមួយអតិថិជន ដូចជាបញ្ជរទូទាត់ ឬមជ្ឈមណ្ឌលព័ត៌មាន។
- ❑ ស្ថានីយ៍ធ្វើការរបស់និយោជិកនៅតាមតំបន់នានា ដូចជាបញ្ជរសំបុត្រ ឬបញ្ជរ ព័ត៌មាន ត្រូវបានបំបែក ដោយយ៉ាងហោចណាស់ ៦ ហ្វីត និងតំបន់រួម ត្រូវបានរៀបចំ ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា យ៉ាងហោចណាស់ ៦ ហ្វីត។
- ❑ និយោជិកត្រូវបានណែនាំអោយរក្សាចម្ងាយយ៉ាងតិចប្រាំមួយ (៦) ហ្វីត ពីអតិថិជន និងពីគ្នាទៅវិញទៅមក។ និយោជិកអាចចូលមកជិតមួយភ្លែត នៅពេលមានការចាំបាច់ ដើម្បីទទួលយកការទូទាត់, ប្រគល់ទំនិញ ឬសេវាកម្ម ឬតាមការចាំបាច់នានា។
- ❑ បន្ទប់សំរាក, បន្ទប់ទឹក និងកន្លែងទូទៅផ្សេងទៀត កំពុងត្រូវបានគេសំឡាប់មេរោគជាញឹកញាប់, តាមកាលវិភាគដូចខាងក្រោមៈ
  - បន្ទប់សំរាក ________________________________________
  - បន្ទប់ទឹក ________________________________________
  - ផ្សេងៗ ________________________________________
- ❑ ការសម្រាកត្រូវបានធ្វើឱ្យបណ្តាក់វេនគ្នា ដើម្បីធានាអោយបាននូវចំងាយ ប្រាំមួយ (6) ហ្វីត រវាងបុគ្គលិក ដែលអាចត្រូវបានរក្សា នៅក្នុងតំបន់សម្រាក ឬបន្ទប់សម្រាក ត្រូវបានកំណត់រៀបចំឡើងវិញ ឬបិទ ដោយមានកន្លែងជំនួសដែលត្រូវបានបង្កើតឡើង សម្រាប់ការសំរាក ដើម្បីអោយមានការនៅឃ្លាតឆ្ងាយពីគ្នា ប្រសិនបើអាចធ្វើទៅបាន។
- ❑ ថ្នាំសំឡាប់មេរោគ និងគ្រឿងផ្គត់ផ្គង់នានា សំរាប់និយោជិកទាំងអស់ អាចរកបានតាមទីតាំងនានា ដូចខាងក្រោមៈ

____________________________________________________

- ❑ ទឹកលាងដៃសំឡាប់មេរោគមានប្រសិទ្ធិភាពប្រឆាំងជំងឺ COVID-19 សំរាប់និយោជិកទាំងអស់ អាចរកបានតាម ទីតាំងនានា ដូចខាងក្រោម៖

---

- ❑ និយោជិកត្រូវបានតំរូវអោយ និងអនុញ្ញាតិអោយមានពេលវេលាគ្រប់គ្រាន់ សម្រាប់លាងដៃរបស់ពួកគេ យ៉ាងហោចណាស់រៀងរាល់ ៣០ នាទីម្តង ឬនៅពេលដែលមានតំរូវការ ប្រសិនបើស្រោមដៃបានត្រូវផ្តល់អោយ។ នៅកន្លែង ដែលការលាងដៃ គឺមិនអាចអនុវត្តបាន, ទឹកផ្ញើអនាម័យដៃ ដែលមានជាតិអាល់កុលយ៉ាងហោចណាស់ ៦០% ត្រូវបានផ្តល់ទៅដល់និយោជិកជំនួសវិញ។
- ❑ កម្មករម្នាក់ៗ ត្រូវបានចាត់តាំងអោយនូវឧបករណ៍, សំភារៈ និងទីកន្លែងធ្វើការងារផ្ទាល់ខ្លួនរបស់ពួកគេ។ និយោជិកទាំងឡាយ ត្រូវបានគេណែនាំអោយ ជៀសវាងការចែករំលែកទូរស័ព្ទ, កុំព្យូទ័របន្ទះ ឬថេប្លេត, វិទ្យុពីរផ្លូវ, ឧបករណ៍ការងារផ្សេងៗ ទៀត, ឬឧបករណ៍ការិយាល័យ នៅពេលណាដែលអាចធ្វើទៅបាន។ ផងដែរ ពួកគេក៏ត្រូវបានណែនាំមិនអោយចែករំលែក PPE ឡើយ។
- ❑ នៅកន្លែងដែលត្រូវចែករំលែករបស់របរនានា, ពួកគេត្រូវបានសំឡាប់មេរោគជាមួយឧបករណ៍សម្អាតដែលសមស្របសម្រាប់ផ្ទៃរវាងការផ្លាស់ប្តូរវេន ឬការប្រើប្រាស់ណាមួយ ដែលញឹកញាប់ខ្លាំង, រួមបញ្ចូលនូវឧបករណ៍ដូចខាងក្រោមនេះ៖ ឧបករណ៍ការិយាល័យរួម, ដូចជាម៉ាស៊ីនថតចំលង, ម៉ាស៊ីនទូរសារ, ម៉ាស៊ីនព្រីនធ័រ, ក្តារចុច, ប្រដាប់កឹប, ប្រដាប់ដកគ្រាប់កឹប, ប្រដាប់បើកសំបុត្រ, ផ្ទៃនៅលើកន្លែងទទួលភ្ញៀវ, ស្ថានីយ៍ការងាររួម, ឧបករណ៍អូឌីយ៉ូស្តាប់ និងវីដេអូ, ឧបករណ៍ជជែកគ្នា ឬអេកូម។ល។
- ❑ ពេលវេលាត្រូវបានផ្តល់ជូននិយោជិក ដើម្បីអនុវត្តនូវការអនុវត្តនូវការសំអាត ក្នុងអំឡុងពេលវេនរបស់ពួកគេ។ ការងារសំអាត ត្រូវបានផ្តល់ឱ្យក្នុងម៉ោងធ្វើការ ដែលជាផ្នែកមួយនៃភារៈកិច្ចការងាររបស់និយោជិក។ កែប្រែម៉ោង, ប្រសិនបើចាំបាច់, ដើម្បីធានាអោយបាននូវការសម្អាតឱ្យបានទៀងទាត់ និងហ្មត់ចត់តាមភាពសមរម្យ។ ជម្រើសអោយមាន នូវលទ្ធកម្មសម្រាប់ក្រុមហ៊ុន សំអាតនៃភាគីទីបី ដើម្បីជួយដល់តម្រូវការសំអាតដែលបានកើនឡើង, ទៅតាមតម្រូវការ។
- ❑ គោលនយោបាយទាំងអស់ ដែលបានពិពណ៌នានៅក្នុងបញ្ជីត្រួតពិនិត្យនេះ ក្រៅពីគោលការណ៍ទាក់ទងនឹងលក្ខ័ណ្ឌនៃការងារ ត្រូវបានអនុវត្តចំពោះបុគ្គលិកនៃការចែកចាយ ឬបញ្ជូន និងក្រុមហ៊ុនផ្សេងណាមួយទៀត ដែលអាចមាននៅក្នុងបរិវេណ ជាភាគីទីបី។
- ❑ ស្រេចលើចិត្ត — ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត:

---

- ❑ បុគ្គលិកត្រូវតែត្រូវបានផ្តល់អោយ នូវ PPE ដែលត្រូវការ ដើម្បីធានាសុខភាពនិងសុវត្ថិភាពរបស់ពួកគេ និងអ្នកបោះជំរុំ។ ពួកគេត្រូវពាក់គំរបមុខ (គ្របមាត់ និងច្រមុះ) ក្នុងកំឡុងពេលកម្មវិធី និងសកម្មភាពទាំងអស់។ គម្របមុខដែលអាចប្រើឡើងវិញ ត្រូវតែត្រូវបានរំងាប់មេរោគ ជារៀងរាល់ថ្ងៃ។
- ❑ បុគ្គលិកអាចត្រូវបានគេតម្រូវឱ្យធ្វើការត្រួតពិនិត្យរាល់ថ្ងៃ ដែលរួមបញ្ចូល ទាំងការត្រួតពិនិត្យសីតុណ្ហភាព ហើយនឹងត្រូវបានផ្តល់ឱ្យនូវ PPE ដែលរួមមាន គំរបមុខ, ស្រោមដៃ និងវ៉ែនតាការពារ។ ការផ្តល់របាំងការពារមុខសម្រាប់កិច្ចការនេះ ត្រូវបានណែនាំ។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- ❑ ការឃ្លាតឆ្ងាយរាងកាយពីគ្នា រវាងបុគ្គលិក និងអ្នកបោះជំរុំ ត្រូវបានរក្សា។
- ❑ អ្នកបោះជំរុំ និងបុគ្គលិកគួរតែត្រូវបានបែងចែកជាក្រុម ដែលមិនមានកុមារ ឬយុវជនលើសពី ១៤ នាក់ និងមិនលើសពីពីរនាក់ដែលជាមនុស្សពេញវ័យ ជាអ្នកត្រួតពិនិត្យ (ចាប់ពីពេលនេះទៅ "ក្រុមមនុស្ស ឬសហករណ៍"), ដែលក្នុងនោះ ត្រួតពិនិត្យមនុស្សពេញវ័យ និងកុមារនៅជាមួយគ្នា ចំពោះគ្រប់សកម្មភាពទាំងអស់ (អាហារ, ការកំសាន្ត, ជាដើម) និង ជៀសវាងការទាក់ទងជាមួយមនុស្សនៅខាងក្រៅក្រុមរបស់ពួកគេនៅក្នុងគ្រឹះស្ថានឬទីកន្លែង។
- ❑ បុគ្គលិកគួរតែនៅជាមួយនឹងក្រុមមនុស្ស ដែលបានចាត់តាំងរបស់ពួកគេ ហើយមិនគួរត្រូវបានចាត់តាំងអោយនូវ មុខងារអ្វីផ្សេងទៀតឡើយ សម្រាប់រយៈពេលនៃការបំពេញនូវការងារនេះ។
- ❑ រៀបចំបន្តបន្ទាប់គ្នានូវពេលវេលាចាប់ផ្តើម សម្រាប់បុគ្គលិក និងបង្កើតនូវការផ្លាស់ប្តូរវេនគ្នា ដើម្បីកំណត់ចំនួនបុគ្គលិក នៅនឹងទីកន្លែង, នៅឯការប្រជុំក្រុម, នៅពេលសំរាកអាហារថ្ងៃត្រង់ និងពេលចេញដំណើរ។ គ្មាននរណាម្នាក់ ត្រូវបានអនុញ្ញាតិឱ្យប្រមូលផ្តុំជាក្រុមឡើយ។
- ❑ បុគ្គលិកត្រូវបានទាមទារ និងអនុញ្ញាតិអោយមានពេលវេលាគ្រប់គ្រាន់ដើម្បីលាងសំអាត ឬធ្វើអនាម័យដៃ រៀងរាល់ ៣០ នាទីម្តង ឬតាមតម្រូវការប្រសិនបើ មានស្រោមដៃបានត្រូវប្រគល់អោយ។ គ្រឿងបរិក្ខារបន្ទប់ចាក់សោរ ត្រូវបានដករបស់របរ ចេញអោយនៅទទេស្អាតទាំងអស់។ ឯកសណ្ឋានបន្ថែម, ប្រដាប់ប្រដារ និងរបស់របរផ្ទាល់ខ្លួនទាំងអស់ អាចរក្សាទុកនៅ ក្នុងយានយន្តផ្ទាល់ខ្លួននៅនឹងកន្លែង។ មិនមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ត្រូវបានអនុញ្ញាតឱ្យរក្សាទុកនៅនឹងកន្លែងឡើយ។
- ❑ មិនអនុញ្ញាតិឱ្យភ្ញៀវទេសចរណ៍ ឬតំណាងអង្គការដែលមិនចាំបាច់ ត្រូវបានអនុញ្ញាតិអោយចូលក្នុងកម្មវិធី ឬតំបន់បុគ្គលិក នៃកន្លែងនោះឡើយ។ នេះរួមបញ្ចូលទាំង អ្នកផ្គត់ផ្គង់ខាងក្រៅ និងសាធារណជនទូទៅ។
- ❑ ការប្រជុំបុគ្គលិក និងការបណ្តុះបណ្តាល ត្រូវបានធ្វើឡើងជាមួយនឹងពិធីការឃ្លាតឆ្ងាយរាងកាយពីគ្នា ឬតាមរយៈ ទូរស័ព្ទ, zoom ឬវេទិកានិម្មិតផ្សេងទៀត។ ការប្រជុំជាក្រុម ជាមួយបុគ្គលិក មកពីក្រុមមនុស្ស ឬសហករណ៍ខុសៗគ្នា ផ្សេងទៀត គួរតែត្រូវបានធ្វើឡើងពីចម្ងាយ, នៅខាងក្រៅ ឬនៅទីធ្លាធំទូលាយ ដូចជាកន្លែងហាត់ប្រាណ ឬបន្ទប់ពហុមុខងារ, ដែលមានបង្អួចបើកចំហរ, តាមដែលអាចធ្វើទៅបាន, ជៀសវាងកន្លែងតូចដែលមានបង្អួចបិទ។ បុគ្គលិកទាំងអស់ត្រូវពាក់គម្របមុខឱ្យបានសមរម្យ និងត្រូវរក្សាគម្លាតរាងកាយ យ៉ាងតិច ៦ ហ្វីត ក្នុងអំឡុងពេលប្រជុំ។
- ❑ ការប្រើប្រាស់ នូវរបស់របរប្រើប្រាស់ក្នុងបន្ទប់សម្រាករួម (ឧទាហរណ៍, ផើងកាហ្វេ, ទូទឹកកក និងមីក្រូវេវ) គួរតែត្រូវបានផ្អាក។ ប្រដាប់ក្លាសេអោយត្រជាក់ផ្ទាល់ខ្លួន ត្រូវបានណែនាំសម្រាប់អាហារ/ ភេសជ្ជៈផ្ទាល់ខ្លួននានា ហើយគួរតែទុកនៅក្នុងយានយន្តផ្ទាល់ខ្លួន។
- ❑ បុគ្គលិក គួរតែទទួលបានការបណ្តុះបណ្តាលនៅក្នុងគោលនយោបាយកម្មវិធីទាំងអស់ រួមទាំងពិធីការសុវត្ថិភាពបន្ថែម។
- ❑ ច្បាប់ចតចំលងនៃពិធីការនេះ ត្រូវបានចែកចាយដល់បុគ្គលិកទាំងអស់។
- ❑ ស្ថាប័ននីមួយៗ ត្រូវតែមានផែនការធានាឱ្យបាននូវបុគ្គលិក ដែលមានភាពសមស្របទៅនឹងសមាមាត្រ របស់អ្នកបោះជំរុំ ប្រសិនបើបុគ្គលិកត្រូវបានគេកំណត់ថាមានអាការៈឈឺ ក្នុងអំឡុងពេលពិនិត្យចំរាញ់សុខភាព, មិនអាចរាយការណ៍ទៅ ធ្វើការនៅថ្ងៃនោះបាន ឬក៏ធ្លាក់ខ្លួនឈឺ ក្នុងអំឡុងពេលវេនរបស់ពួកគេ។
- ❑ ប្រសិនបើបុគ្គលិកបង្ហាញសញ្ញានៃជំងឺ អំឡុងពេលវេនការងារ, ត្រូវដាក់បុគ្គលិកនៅកន្លែងទំនេរឯកោ ដែលបានកំណត់ជាមុន។ ចាត់តាំងបុគ្គលិកបន្ថែម ដើម្បីធានាថាបុគ្គលិក និងអ្នកបោះជំរុំមានសមាមាត្រគ្នា ប្រសិនបើចាំបាច់។ អង្គការ

នីមួយៗ នឹងត្រូវបានតម្រូវឱ្យយោងគោលការណ៍ណែនាំធនធានមនុស្ស ឬនាយកដ្ឋានបុគ្គលិករបស់ពួកគេ។

- ❑ អង្គការនានាត្រូវបានណែនាំឱ្យប្រកាន់ខ្ជាប់នូវផែនការ ជំងឺឆ្លងរបស់ពួកគេ និងធ្វើការទាក់ទង ជាមួយនឹងអ្នកគ្រប់គ្រងរបស់ពួកគេ, ឪពុកម្តាយរបស់អ្នកបោះជំរុំ, អាណាព្យាបាល ឬអ្នកមើលថែ, ប្រសិនបើអាចអនុវត្តបាន, និងតាមដានជាមួយ នាយកដ្ឋានសុខភាពឡុងប៊ិចរបស់អ្នកជាបន្ទាន់ ដើម្បីទទួលបានការណែនាំបន្ថែម ប្រសិនបើបុគ្គលិកត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញថាមានជម្ងឺ COVID-19។
- ❑ និយោជិកទាំងឡាយត្រូវបានរំលឹក អោយប្រកាន់ខ្ជាប់នូវសកម្មភាពការពារផ្ទាល់ខ្លួន រួមមាន:
  - ❑ ស្នាក់នៅផ្ទះ នៅពេលដែលអ្នកឈឺ។ ស្នាក់នៅផ្ទះយ៉ាងហោចណាស់ ៣ ថ្ងៃ (៧២ ម៉ោង) បន្ទាប់ពីការជាសះស្បើយ, ដែលមានន័យថា គ្រុនក្តៅរបស់អ្នកបានត្រូវដោះស្រាយ ដោយមិនចាំបាច់ប្រើថ្នាំបន្ថយកំដៅទេ ហើយ វាមានភាពប្រសើរឡើង នៃរោគសញ្ញាផ្លូវដង្ហើមនានារបស់អ្នក (ឧទាហរណ៍., ក្អក, ដង្ហើមខ្លី ឬដង្ហក់), និងយ៉ាងហោចណាស់ ១០ ថ្ងៃបានកន្លងផុតទៅ តាំងតែពីរោគសញ្ញាដំបូងរបស់អ្នកបានបង្ហាញចេញមក
  - ❑ លាងដៃរបស់អ្នកអោយបានញឹកញាប់ ជាមួយសាប៊ូ និងទឹក យ៉ាងហោចណាស់ ២០ វិនាទី។ ប្រសិនបើមិនមានសាប៊ូ និងទឹកទេនោះ, សូមប្រើទឹកលាងដៃអនាម័យដែលមានជាតិអាល់កុល យ៉ាងហោចណាស់ ៦០%។ លាងដៃរបស់អ្នក មុនពេលញ៉ាំអាហារ, បន្ទាប់ពីប្រើបន្ទប់ទឹករួច និងក្រោយពេលក្អក និងកណ្តាស់។
  - ❑ ខ្ទប់ក្អក និងកណ្តាស់របស់អ្នក ជាមួយនឹងក្រដាសស្តើង ហើយបន្ទាប់មក បោះក្រដាសស្តើងនោះចោល ហើយសម្អាតដៃរបស់អ្នកភ្លាមៗ។ ប្រសិនបើអ្នកមិនមានក្រដាសស្តើងទេនោះ សូមប្រើកែងដៃរបស់អ្នក (មិនមែនដៃរបស់អ្នកទេ)។
  - ❑ កុំប៉ះពាល់មាត់, ភ្នែក, ច្រមុះរបស់អ្នក ដោយដៃដែលមិនទាន់លាងសំអាត។
  - ❑ ជៀសវាងការទំនាក់ទំនង ឬប៉ះពាល់ជាមួយមនុស្សឈឺ។
  - ❑ ជៀសវាងការចែករំលែករបស់របរប្រើប្រាស់ ដូចជាទូរស័ព្ទ ឬឧបករណ៍ផ្សេងៗទៀត។ ប្រសិនបើឧបករណ៍ ត្រូវតែចែករំលែក ត្រូវធ្វើអោយប្រាកដថា ជូតសំអាតវា ដោយប្រើប្រដាប់ជូតសំឡាប់មេរោគ មុន និងក្រោយ ពេលចែករំលែក។
  - ❑ សង្កេតជានិច្ច នូវចម្ងាយការងាររបស់អ្នក នៃទំនាក់ទំនងជាមួយនឹងបុគ្គលិកផ្សេងទៀត។ ត្រូវរក្សាការនៅដាច់ឆ្ងាយពីគ្នាដែលបានណែនាំ យ៉ាងតិចបំផុត ៦ ហ្វីត ពីអ្នកដទៃ លើកលែងតែការងារជាក់លាក់ដែលតម្រូវអោយមានចំងាយតិចជាង ហើយត្រូវពាក់គម្របមុខ នៅពេលធ្វើការជិត ឬជាមួយអ្នកដទៃ។

## B. តំរូវការនៃការពិនិត្យ ឬឆែកឆេអ្នកបោះជំរុំចូល និងចេញ

- ❑ កំណត់ពេលតៗគ្នានៃការមកដល់/ទម្លាក់ចុះ និងការមកទទួលយកអ្នកបោះជំរុំ ឬចុះហត្ថលេខាចេញ ឬទីតាំង,

ឬដាក់ចេញនូវពិធីការផ្សេងទៀត ដើម្បីកំរឹតនូវការប៉ះពាល់ផ្ទាល់រវាងឪពុកម្តាយ/អ្នកមើលថែ នៃគ្រួសារនីមួយៗ

- ❑ កន្លែងឆែកឆេ ឬពិនិត្យចូល និងចេញ ត្រូវតែគូសឬដាក់សញ្ញា សម្គាល់យ៉ាងច្បាស់ដើម្បីបង្ហាញពីការឃ្លាតឆ្ងាយរាងកាយពីគ្នា។
- ❑ ឪពុកម្តាយ ឬអ្នកមើលថែ ត្រូវប្រើប៊ិចផ្ទាល់ខ្លួន នៅពេលចុះឈ្មោះអ្នកបោះជំរុំចូលឬ ចេញ ឬបុគ្គលិកត្រូវរំងាប់មេរោគលើប៊ិចចេញ រវាងការប្រើប្រាស់នីមួយៗ។ ប្រសិនបើ ប្រើប្រព័ន្ធត្រួតពិនិត្យ ឬការចុះឈ្មោះចូល និងចេញបែបឌីជីថល, បុគ្គលិកត្រូវតែរំងាប់មេរោគផ្ទៃកនានាដែលបានប៉ះពាល់ រវាងការប្រើប្រាស់។
- ❑ បុគ្គលិកដែលធ្វើការពិនិត្យសុខភាព ត្រូវតែពាក់ PPE ដែលសមរម្យ រួមមានគម្របមុខ, ស្រោមដៃ និង / ឬវ៉ែនតាការពារ។ របាំងមុខ ត្រូវបានណែនាំយ៉ាងខ្លាំង ជាការការពារបន្ថែម។
- ❑ រឹតបន្តឹងពេលវេលាឪពុកម្តាយ ឬអ្នកមើលថែ ដែលបានចំណាយនៅឯកន្លែងការងារសំខាន់ៗតែប៉ុណ្ណោះ។

## C. តម្រូវការចំណីអាហារ, អាហារសំរន់ និងសេវាកម្មអាហារ

- ❑ ប្រសិនបើអាហារ ឬអាហារសម្រន់ ត្រូវបានផ្តល់អោយ ជាផ្នែកមួយនៃកម្មវិធី ដូចជាកម្មវិធីអាហារថ្ងៃត្រង់ និងអាហារសម្រន់ ដោយឥតគិតថ្លៃ និងចុះថ្លៃ, វាត្រូវតែរៀបចំដាក់ក្នុងកញ្ចប់ ជាមុន។
- ❑ ប្រសិនបើអ្នកបោះជំរុំ នាំយកអាហារថ្ងៃត្រង់ និង/ឬ អាហារសម្រន់ផ្ទាល់ខ្លួនរបស់ពួកគេមកជាមួយ, វាត្រូវតែយកមកដោយដាក់ក្នុងថុងមួយ ដែលមានដាក់ផ្លាកឈ្មោះអ្នកបោះជំរុំ ហើយរក្សាទុកជាមួយរបស់របរនានា ផ្ទាល់ខ្លួន។
- ❑ កំណត់ពេលតៗគ្នានៃការញ៉ាំអាហាររវាងក្រុមមនុស្សជំរុំនីមួយៗ និងអ្នកបោះជំរុំខាងក្រៅប្រ សិនបើទីតាំងជាផ្នែកមួយ នៃ កម្មវិធីចែកចាយអាហារ។
- ❑ ក្រុមមនុស្ស ឬសហករណ៍គួរនៅជាមួយគ្នា ដើម្បីទទួលទានអាហារ និងចៀសវាងការទទួលទានអាហារជាមួយមនុស្សដែលនៅខាងក្រៅក្រុមមនុស្សឬសហករណ៍ របស់ពួកគេ
- ❑ តំបន់អាហារថ្ងៃត្រង់និ ងអាហារសម្រន់ ត្រូវតែត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវការឃ្លាតឆ្ងាយរាងកាយពីគ្នា រវាងអ្នកបោះជំរុំនិមួយៗ និងត្រូវបានរំងាប់មេរោគ និងធ្វើអនាម័យ ដោយបុគ្គលិកបន្ទាប់ពីការប្រើប្រាស់ម្តងៗ។
- ❑ ប្រសិនបើ បុគ្គលិកត្រូវការចែកចាយ ឬធ្វើការជាមួយអាហារ, បុគ្គលិកត្រូវពាក់គំរបមុខ និងស្រោមដៃ។
- ❑ កំណត់ពេលលាងដៃ មុន និងក្រោយពេលបរិភោគ។
- ❑ អាហារអាចមិនត្រូវបានចែករំលែក ក្នុងចំណោមអ្នកបោះជំរុំឡើយ។
- ❑ ប្រើប្រដាប់ប្រដារចំអិន ឬហូបចុក ដែលអាចបោះចោលបាន និងទំនិញក្រដាស់។
- ❑ កុំចែករំលែកប្រដាប់ប្រដាចំអិន ឬហូបចុក ។
- ❑ ផ្តល់នូវទឹកធ្វើអនាម័យតាមដៃ មុន និងកំឡុងពេលសកម្មភាពអាហារ និងចំណីអាហារ។
- ❑ ទូរទឹកកក និងកន្លែងស្តុកទុកផ្សេងទៀត ត្រូវតែសម្អាតជារៀងរាល់ថ្ងៃ។

## D. ការរៀបចំក្រុម/សកម្មភាពនានា/ឧបករណ៍ និងការត្រួតពិនិត្យ

- ❑ អ្នកបោះជំរុំ គួរតែស្ថិតនៅក្នុងកន្លែងតែមួយ និងជាក្រុមមនុស្ស ឬសហការណ៍តូច និងស្ថិតស្ថេរ តាមដែលអាចអនុវត្តទៅបាន។ រក្សាអ្នកបោះជំរុំ និងបុគ្គលិកជាមួយក្រុមមនុស្សនីមួយៗ និងរាប់បញ្ចូលអ្នកបោះជំរុំពីក្រុមគ្រួសារតែមួយ ក្នុងក្រុមមនុស្សតែមួយ, អោយបានច្រើនបំផុតដែលអាចអនុវត្តទៅបាន។ អ្នកចូលរួម បានត្រូវណែនាំ អោយមានសមាមាត្រធៀបទៅនឹងបុគ្គលិក ចំនួន ១៤:១។ លើក លែងតែជំរុំកីឡានានា ដែលផ្តោតលើជំនាញ, ដែលគួរតែប្រកាន់ខ្ជាប់នូវអ្នកចូលរួម ៦:១ នាក់ ចំពោះសមាមាត្របុគ្គលិក។
- ❑ វាត្រូវបានផ្តល់អនុសាសន៍ឱ្យទុកអ្នកបោះជំរុំក្នុងគ្រួសារតែមួយ ក្នុងក្រុមមនុស្សតែមួយ នៅពេលណាដែលអាចធ្វើទៅបាន ដោយមិនលើសពីសមាមាត្រដែលបានកំនត់។
- ❑ ក្រុមមនុស្សក្នុងកម្មវិធីនីមួយៗ ត្រូវតែត្រូវបានចាត់តាំងឱ្យបែងចែកបន្ទប់ ឬកន្លែងទំនេរដែល មានការអនុវត្តនូវពិធីការគំលាតឆ្ងាយរាងកាយពីគ្នា។ ប្រសិនបើទីធ្លាក្នុងផ្ទះត្រូវបានប្រើដោយក្រុមមនុស្សជាច្រើន នៅពេលខុសគ្នា, បុគ្គលិកត្រូវតែធ្វើអនាម័យកន្លែងដែលមានការប៉ះពាល់ទូទៅ នៃបន្ទប់ រវាងការប្រើប្រាស់។
- ❑ អ្នកបោះជំរុំ ត្រូវបានលើកទឹកចិត្តឱ្យពាក់គំរបមុខក្នុងពេលធ្វើសកម្មភាពជាក្រុម, លើកលែងតែពេលបរិភោគ, ឬចូលរួមសកម្មភាពតឹងរឹង ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការដកដង្ហើម។ អ្នកបោះជំរុំ មកពីក្រុមមនុស្សផ្សេងៗគ្នា មិនគួរអោយលាយឡំបញ្ចូលគ្នាឡើយ តាមដែលអាចធ្វើទៅបានទេ។
- ❑ រៀបចំផែនការសកម្មភាពនានា ដែលមិនត្រូវការប៉ះពាល់រាងកាយជិតស្និទ្ធ រវាងអ្នកបោះជំរុំច្រើនគ្នា។
- ❑ កំណត់ពេលតៗគ្នានៃការលេងកម្សាន្តក្នុងផ្ទះ និងក្រៅផ្ទះ និងកន្លែងដែលចែករំលែកគ្នា; កែសម្រួលកាលវិភាគដើម្បីកាត់បន្ថយចំនួនអ្នកបោះជំរុំ ក្នុងតំបន់តែមួយ។
- ❑ រាល់ដំណើរកំសាន្ត និងសកម្មភាពនានា ដែលត្រូវការ ការធ្វើដំណើរ ត្រូវតែអនុវត្តយ៉ាងពេញលេញជាមួយនឹង ការឃ្លាតឆ្ងាយរាងកាយពីគ្នា និងវិធានការណ៍សម្រាប់ការត្រួតពិនិត្យការឆ្លង ខាងក្រោម។
- ❑ កំណត់ពេលវេលាលាងដៃញឹកញាប់ យ៉ាងហោចណាស់រវាងសកម្មភាព និងការវិលជុំ លេងក្រៅផ្ទះ, បន្ទប់ទឹក និងពេលសំរាកអាហារ។
- ❑ ប្រសិនបើមានកន្លែងអខ្វាទិច ឬកន្លែងដែលមានទឹកលេង, ប្រតិបត្តិករកម្មវិធី ត្រូវតែប្រកាន់ខ្ជាប់នូវពិធីការសម្រាប់អាងហែលទឹកសាធារណៈ (ឧបសម្ព័ន្ធ K)។
- ❑ ប្រសិនបើអ្នកបោះជំរុំ បង្ហាញពីសញ្ញានៃជំងឺ, សូមប្រើតំបន់ដាច់ស្រយាលដែលបានកំណត់ជាមុនដើម្បីញែកអ្នកបោះជំរុំ ពីក្រុមប្រជាជនទូទៅ និងជូនដំណឹងដល់អ្នកថែទាំភ្លាមៗដើម្បីទៅទទួលយក។
- ❑ អ្នកបោះជំរុំម្នាក់ ដែលត្រូវបានគេរកឃើញថាមានវិជ្ជមាននៃជំងឺ COVID-19 មិនត្រូវវិលត្រឡប់ ចូលមកកាន់កម្មវិធីវិញទេ យ៉ាងហោចណាស់រយៈពេល ១ ថ្ងៃ (២៤ ម៉ោង) បានកន្លងផុតទៅ ចាប់តាំងពីការជាសះស្បើយរបស់អ្នកបោះជំរុំ, ដែលត្រូវបានកំណត់ថាជាដំណោះស្រាយគ្រុនក្តៅ ដោយមិនប្រើថ្នាំបន្ថយគ្រុនក្តៅ និងធ្វើឱ្យប្រសើរឡើង នៃរោគសញ្ញានានា (ឧទាហរណ៍., ក្អក, ដង្ហើមខ្លី ឬដង្ហក់), និងយ៉ាងហោចណាស់ ១០ ថ្ងៃ ចាប់តាំងពីរោគសញ្ញាជំងឺ

COVID-19 បានបង្ហាញជាលើកដំបូង។ ប្រសិនបើអ្នកបោះជំរុំ មិនដែលមានរោគសញ្ញា, បន្ទាប់មកពួកគេមិនត្រូវត្រឡប់មកវិញរហូតដល់ចំនួន ១០ ថ្ងៃបានកន្លងផុតទៅចាប់តាំងពីថ្ងៃ នៃការធ្វើរោគវិនិច្ឆ័យថាមាន វិជ្ជ មានជំងឺ COVID-19 ដំបូងរបស់ពួកគេ សន្មតថាពួកគេមិនបានបង្កើតរោគសញ្ញានានាជាបន្តបន្ទាប់ ចាប់តាំងពីការ ធ្វើតេស្តវិជ្ជមានរបស់ពួកគេ។ អនុវត្តតាមពិធីការ នៃការប្រាស្រ័យទាក់ទងដោយអនុលោមតាមផែនការបង្ការជំងឺ ឆ្លង(CDP) របស់អង្គការរបស់អ្នក ដែលអាចរាប់បញ្ចូល ទាំងការទំនាក់ទំនងអ្នកគ្រប់គ្រង និង/ឬមន្ត្រីមន្ទីរសុខា ភិបាលឡុងប៊ិច ដើម្បីស្វែងរកការណែនាំបន្ថែម។

- ❑ មានផែនការនឹងបិទកម្មវិធី និង/ឬកន្លែងភ្លាមៗ ប្រសិនបើមន្ទីរសុខាភិបាលឡុងប៊ិច យល់ថាចាំបាច់។
- ❑ វាត្រូវបានផ្តល់អនុសាសន៍ឱ្យជៀសវាងការរៀបចំកម្មវិធី និងសកម្មភាពនានា ដែលត្រូវការការប្រើប្រាស់ឧបករណ៍ រួមគ្នា។ ប្រសិនបើអាចធ្វើទៅបាន, សូមផ្គត់ផ្គង់សំភារៈសិក្សា និងឧបករណ៍គ្រប់គ្រាន់, និងប្រដាប់ប្រដាប្រើប្រាស់ ជាលក្ខណៈបុគ្គល សម្រាប់អ្នកបោះជំរុំទាំងអស់។
- ❑ ឧបករណ៍និងហ្គេមដែលបានចែករំលែក គួរតែត្រូវបានសម្អាត, ការធ្វើអនាម័យ, និងរំងាប់មេរោគ ឱ្យបានញឹកញាប់ នៅដើមថ្ងៃ និងពេលប្រើដោយអ្នកបោះជំរុំផ្សេងៗគ្នា។

## E. វិធានការណ៍នានា សំរាប់គ្រប់គ្រងការឆ្លង

- ❑ ធានាថាបុគ្គលិក និងក្រុមគ្រួសារជំរុំទាំងអស់ បានយល់ដឹងអំពីការពង្រឹងការអនុវត្តអនាម័យ, គោលការណ៍ណែនាំនៃការឃ្លាតឆ្ងាយរាងកាយពីគ្នា និងសារៈសំខាន់, ការប្រើប្រាស់ត្រឹមត្រូវ, ការដោះចេញ និងបោកគក់គម្របមុខ ក្រណាត់, ការអនុវត្តន៍ការការត្រួតពិនិត្យ និងលក្ខណៈវិនិច្ឆ័យការបដិសេធដាក់លាក់នៃជំងឺ COVID-19។
- ❑ ចាត់តាំងបុគ្គលិក (ឧទាហរណ៍, គិលានុបដ្ឋាយិកាជំរុំ ឬអ្នកផ្តល់សេវាថែទាំសុខភាព) ឱ្យទទួលខុសត្រូវក្នុងការឆ្លើយតបទៅនឹងបញ្ហា ឬកង្វល់នានានៃជំងឺ COVID-19។ បុគ្គលិកជំរំ និងក្រុមគ្រួសារទាំងអស់ គួរតែដឹងថា តើ បុគ្គលនេះជានរណា និងរបៀបទាក់ទងពួកគេ។ បុគ្គលនេះ គួរតែត្រូវបានបណ្តុះបណ្តាលឱ្យសម្របសម្រួលឯកសារ និងតាមដានការប្រឈម ដែលអាចកើតមាន, ដើម្បីជូនដំណឹងដល់មន្ទីរសុខាភិបាលឡុងប៊ិច, បុគ្គលិក និងក្រុម គ្រួសារ នៅក្នុងលក្ខណៈបន្ទាន់ និងការទទួលខុសត្រូវ។
- ❑ សម្រាប់តំបន់ដែលមានការបែងចែកភូមិសាស្ត្រធំធេង, សូមពិចារណាការរឹតត្បិតការចូលរួមរបស់អ្នកបោះជំរុំ ដែលរស់នៅក្នុងតំបន់ភូមិសាស្ត្រ ក្នុងតំបន់ ហើយស្នើសុំឱ្យអ្នកបោះជំរុំចៀសវាងចលនារវាងជំរុំនានា។
- ❑ ធានាការផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់ ដើម្បីគាំទ្រនូវឥរិយាបថអនាម័យដែលមានសុខភាពល្អ, រួមមានសាប៊ូ, ក្រដាស់ស្តើង, ធុងសំរាបមិនប៉ះពាល់ និងទឹកធ្វើអនាម័យដៃ ដែលមានជាតិអាល់កុលអេទីល យ៉ាងហោចណាស់ ៦០ ភាគរយសម្រាប់បុគ្គលិក និងអ្នកបោះជំរុំទាំងឡាយណា ដែលអាចប្រើប្រាស់ទឹកធ្វើអនាម័យដៃបានដោយសុវត្ថិភាព។
- ❑ បង្រៀនអ្នកបោះជំរុំ នូវវិធានការការពារផ្ទាល់ខ្លួន ដូចខាងក្រោម

- លាងដៃឱ្យបានទៀងទាត់ មុន និងក្រោយ ពេលបរិភោគ; បន្ទាប់ពីក្អក ឬកណ្តាស់; បន្ទាប់ពីនៅខាងក្រៅផ្ទះ; ហើយបន្ទាប់ពីប្រើបន្ទប់ទឹករួច។
- ជៀសវាងការប៉ះភ្នែក, ច្រមុះ និងមាត់របស់អ្នក
- ខ្ទប់ក្អក និងកណ្តាស់
- ប្រើក្រដាស់ស្តើងដើម្បីជូតច្រមុះ និងក្អក/កណ្តាស់របស់អ្នក នៅក្នុងក្រដាស់ស្តើង ឬកែងដៃ។

- ❑ ពិចារណាពីទម្លាប់ដែលអាចធ្វើឱ្យបុគ្គលិកជំរុំ និងអ្នកបោះជំរុំលាងដៃរបស់ពួកគេ ឱ្យបានទៀងទាត់ នៅចន្លោះពេលបន្តបន្ទាប់គ្នា។
- ❑ អ្នកបោះជំរុំ និងបុគ្គលិក គួរលាងដៃរយៈពេល ២០ វិនាទី ជាមួយសាប៊ូ, ដុសខាត់យ៉ាងហ្មត់ចត់ បន្ទាប់ពីប្រតិបត្តិការរួច, និងប្រើកន្សែងក្រដាស់ (ឬប្រើកន្សែងក្រណាត់ដែលប្រើបានតែម្តង) ដើម្បីសំងួតដៃឱ្យស្ងួត។
- ❑ បុគ្គលិកគួរបង្ហាញគំរូ និងអនុវត្តនូវការលាងដៃ។ ឧទាហរណ៍, សម្រាប់អ្នកបោះជំរុំវ័យក្មេង, ប្រើពេលវេលាបន្ទប់ទឹកជាឱកាសមួយ ដើម្បីពង្រឹងទម្លាប់ល្អ និងសង្កេតការលាងដៃឱ្យបានត្រឹមត្រូវ។
- ❑ អ្នកបោះជំរុំ និងបុគ្គលិក គួរប្រើទឹកធ្វើអនាម័យដៃ នៅពេលដែលការលាងដៃ មិនអាចអនុវត្តបាន។ ទឹកធ្វើអនាម័យដៃត្រូវតែត្រដុសចូលក្នុងដៃ រហូតទាល់តែវាស្ងួតទាំងស្រុង។ សម្គាល់: ការលាងដៃញឹកញាប់ គឺមានប្រសិទ្ធភាពជាងការប្រើប្រាស់ទឹកធ្វើអនាម័យដៃ, ជាពិសេសនៅពេលដែលដៃមើលឃើញកខ្វក់។
- ❑ កុមារអាយុក្រោម ៩ ឆ្នាំ គួរប្រើទឹកធ្វើអនាម័យដៃ ក្រោមការត្រួតពិនិត្យរបស់មនុស្សពេញវ័យ។ ហៅទូរស័ព្ទទៅកាន់ការត្រួតពិនិត្យថ្នាំពុល ប្រសិនបើបានបរិភោគ: 1-800-222-1222។ ទឹកធ្វើអនាម័យដៃដែលមានជាតិអាល់កុលអេទីលគឺមានការចូលចិត្ត ហើយគួរតែត្រូវ បានប្រើនៅពេលមានសក្តានុពលនៃការប្រើប្រាស់ដែលមិនត្រូវបានត្រួតពិនិត្យដោយកុមារ។ ទឹកធ្វើអនាម័យដៃ Isopropyl មានជាតិពុលច្រើន ហើយអាចស្រូបចូលតាមស្បែក។
- ❑ ពិចារណាស្ថានីយ៍លាងដៃចល័តនៅគ្រប់ទីកន្លែង ដើម្បីកាត់បន្ថយចលនា និងកន្លែងប្រជុំនៅក្នុងបន្ទប់ទឹក ឱ្យបានតិចបំផុត តាមដែលអាចធ្វើទៅបាន។
- ❑ តំរូវអោយអ្នកបោះជំរុំ ពាក់គំរបមុខក្រណាត់ ដូចដែលបានចែងនៅក្នុងបទបញ្ជា មានសុវត្ថិភាពជាង ពេលនៅផ្ទះ ។
- ❑ ផ្អាកការប្រើប្រាស់ប្រភពទឹកផឹក ឬក្បាលរូប៊ីណេទឹកផឹក ហើយជំនួសមក វិញលើកទឹកចិត្តឱ្យប្រើដបទឹកដែលអាចប្រើឡើងវិញបាន។
- ❑ ផ្ទៃដែលត្រូវបានប៉ះពាល់ញឹកញាប់ ដូចជាដៃ ទ្វារ, ឧបករណ៍ប្តូរពន្លឺ, ដៃស្នូកទឹក, បន្ទប់ទឹក, ផ្ទៃនានា, តុ ក៏ដូចជា ផ្ទៃក្នុងយានយន្តដឹកជញ្ជូន គួរតែត្រូវសម្អាតឱ្យបាន យ៉ាងហោចណាស់រៀងរាល់ថ្ងៃ និងញឹកញាប់អោយបានពេញ មួយថ្ងៃ ប្រសិនបើអាច។
- ❑ កំណត់ការប្រើប្រាស់ឧបករណ៍ចែករំលែក ដែលគាំទ្រដល់សកម្មភាពរាងកាយនានា ដែលត្រូវការនូវការប៉ះពាល់តិចជាមួយនឹងផ្ទៃ។ ការប្រើប្រាស់ឧបករណ៍ទីធ្លាកំសាន្តឬសួនកុមារ នៅខាងក្នុង ត្រូវបានហាមឃាត់។ ទីធ្លាកំសាន្តខាងក្រៅអាចបើក តាមការសំរេចចិត្តរបស់ប្រតិបត្តិករ ទៅតាមសេចក្តីណែនាំរបស់រដ្ឋ ដែលមាន ឬរកឃើញនៅទីនេះ។

- ❑ កំណត់ការចែករំលែកវត្ថុ និងឧបករណ៍, ដូចជាប្រដាប់ប្រដាក្មេងលេង, ហ្គេម និងគ្រឿងផ្គត់ផ្គង់សិល្បៈ, បើមិនដូច្នេះទេ ត្រូវសម្អាត និងរំងាប់មេរោគ រវាងការប្រើប្រាស់។
- ❑ នៅពេលជ្រើសរើសផលិតផលសម្អាត, សូមប្រើផលិតផលដែលត្រូវបានអនុម័តអោយប្រើប្រាស់ប្រឆាំងនឹងជំងឺ COVID-19 នៅលើទីភ្នាក់ងារការពារបរិស្ថាន Environmental Protection Agency (EPA) ដែលបានអនុម័តលើបញ្ជី "N" ហើយធ្វើតាមការណែនាំផលិតផលផ្សេងៗ។ ផលិតផលទាំងនេះមានផ្ទុកនូវគ្រឿងផ្សំ ដែលមានសុវត្ថិភាពជាង សម្រាប់អ្នកដែលមានជំងឺហឺត។
- ❑ ប្រើថ្នាំរំងាប់មេរោគ ដែលមានស្លាកសញ្ញា ដើម្បីឱ្យមានប្រសិទ្ធភាពប្រឆាំងនឹងភ្នាក់ងារបង្ករោគ ដែលកំពុងលេចចេញ, តាមការណែនាំស្លាកសញ្ញា សម្រាប់អត្រារំលាយសមស្រប និងពេលវេលាទំនាក់ទំនង។ ផ្តល់ការបណ្តុះបណ្តាលដល់និយោជិក អំពីគ្រោះថ្នាក់នៃសារធាតុគីមី, ការណែនាំរបស់អ្នកផលិត, និងតម្រូវការ Cal/OSHA សម្រាប់ការប្រើប្រាស់ប្រកបដោយសុវត្ថិភាព។
- ❑ បុគ្គលិកយាម ឬថែទាំដែលមានទំនួលខុសត្រូវក្នុងការសម្អាត និងរំងាប់មេរោគកន្លែង ត្រូវតែបំពាក់ដោយឧបករណ៍ការពារត្រឹមត្រូវ រួមមានស្រោមដៃ, ការពារភ្នែក, ការពារដង្ហើម, និងឧបករណ៍ការពារសមស្របផ្សេងទៀត តាមតម្រូវការ នៃសេចក្តីណែនាំផលិតផល។ រាល់ផលិតផលទាំងអស់ ត្រូវរក្សាទុកឱ្យឆ្ងាយពីដៃកុមារដែលអាចឈោងដល់ និងរក្សាទុកក្នុងទីធ្លាដែលសិទ្ធិចូលប្រើ មានការរឹតបន្តឹងឬមានកម្រិត។
- ❑ នៅពេលសម្អាតខ្យល់ចេញទីធ្លាមុនពេលអ្នកបោះជំរុំមកដល់; មានគម្រោងធ្វើអនាម័យយ៉ាងហ្មត់ចត់ នៅពេលអ្នកបោះជំរុំ មិនមានវត្តមាន។ ប្រសិនបើប្រើម៉ាស៊ីនត្រជាក់, សូមប្រើការកំណត់ដែលនាំមកនូវខ្យល់បរិសុទ្ធ។ ជំនួស និងពិនិត្យប្រព័ន្ធត្រងនិងប្រព័ន្ធត្រងខ្យល់ ដើម្បីធានាបាននូវគុណភាពខ្យល់ល្អបំផុត។
- ❑ ប្រសិនបើការបើកបង្អួច បង្កនូវសុវត្ថិភាព ឬសុខភាព, ពិចារណាយុទ្ធសាស្ត្រជំនួស ដើម្បី ធ្វើឱ្យប្រសើរឡើងនូវលំហូរខ្យល់ ដូចជាការត្រងខ្យល់កណ្តាលឱ្យបានអតិបរិមាសម្រាប់ប្រព័ន្ធ HVAC (ការវាយតម្លៃតម្រងគោលដៅ យ៉ាងហោចណាស់ MERV 13)។
- ❑ ចាត់វិធានការដើម្បីធានាថា ប្រព័ន្ធទឹក និងផ្នែកសំខាន់នានា (ឧទាហរណ៍, ប្រភពឬក្បាលរូប៊ីណេទឹកផឹក, ប្រភពទឹកតុបតែង) មានសុវត្ថិភាពក្នុងការប្រើប្រាស់ បន្ទាប់ពីការបិទទីតាំងយូរ ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លង ដូចជាជំងឺរលាកសួតធ្ងន់ធ្ងរ (Legionnaires)។

## ត្រួតពិនិត្យ ឬចំរាញ់អ្នកបោះជំរុំ

- ❑ បណ្តុះបណ្តាលបុគ្គលិក និងអប់រំអ្នកបោះជំរុំ និងគ្រួសារ អំពីពេលវេលាណា ដែលពួកគេគួរនៅផ្ទះ ហើយពេលណាដែលពួកគេអាចត្រឡប់មកជំរុំវិញ។ ធ្វើសកម្មភាពលើកទឹកចិត្តយ៉ាងសកម្មដល់បុគ្គលិកនិងអ្នកបោះជំរុំ ដែលឈឺឬដែលទើបនឹងមានទំនាក់ទំនងជិតស្និទ្ធ ជាមួយមនុស្សដែលមានជំងឺ COVID-19 អោយស្នាក់នៅផ្ទះ។
- ❑ បន្ថែមលើការត្រួតពិនិត្យបុគ្គលិក នៅពេលពួកគេមកដល់, អ្នកបោះជំរុំទាំងអស់ ក៏ត្រូវត្រួតពិនិត្យ ឬចំរាញ់ ផងដែរ នៅពេលមកដល់កន្លែង។

  - ពិចារណាធ្វើការត្រួតពិនិត្យសុខភាពរបស់អ្នកបោះជំរុំទាំងអស់ តាមការមើលឃើញដោយភ្នែកទទេ នៅពេលមកដល់។ នេះអាចរាប់បញ្ចូលទាំងសីតុណ្ហភាពរបស់អ្នកបោះជំរុំ នៅដើមថ្ងៃនីមួយៗ ដោយមិនមានទែម៉ូម៉ែត្រ ប៉ះរូបគេនោះឡើយ។ ប្រសិនបើមិនមានទែម៉ូម៉ែត្រដែលមិនបាច់ប៉ះនោះទេ, ការរាយការណ៍នៃការវាយតម្លៃសីតុណ្ហភាពអាចទទួលយកបាន។
  - សាកសួរបុគ្គលទាំងអស់អំពីរោគសញ្ញានានានៃជំងឺ COVID-19 ក្នុងរយៈពេល ២៤ ម៉ោងចុងក្រោយ និងថាតើ មាននរណាម្នាក់នៅក្នុងផ្ទះរបស់ពួកគេ មានរោគសញ្ញានៃជម្ងឺ COVID-19 ឬក៏មានតេស្តវិជ្ជមាន។

- ❑ មិនរាប់បញ្ចូលកុមារ, ឪពុកម្តាយ, អ្នកមើលថែ ឬបុគ្គលិកណា ដែលបង្ហាញរោគសញ្ញានៃជំងឺ COVID-19 នោះឡើយ។
- ❑ ត្រួតពិនិត្យបុគ្គលិក និងអ្នកបោះជំរុំពេញមួយថ្ងៃដើម្បីមើលរករោគសញ្ញានៃជំងឺ; បញ្ជូនអ្នកបោះជំរុំ និងបុគ្គលិកទៅផ្ទះចំពោះអ្នកដែលមានគ្រុនក្តៅ ១០០.៤ ដឺក្រេ ឬខ្ពស់ជាងនេះ, ក្អក ឬរោគសញ្ញាជំងឺ COVID-19 នានាផ្សេងទៀត។ បញ្ជូនមនុស្សទៅកន្លែងវេជ្ជសាស្ត្រ ដែលសមរម្យជាជាងទៅកាន់ផ្ទះរបស់ពួកគេ ប្រសិនបើចាំបាច់។

## ប្រសិនបើបុគ្គលិក ឬអ្នកបោះជំរុំធ្លាក់ខ្លួនឈឺ

- ❑ កំណត់បន្ទប់ ឬតំបន់ដាច់ដោយឡែក ដើម្បីបំបែកអ្នកណាម្នាក់ ដែលបង្ហាញរោគសញ្ញានៃជំងឺ COVID-19។ (គ្រុនក្តៅ, ក្អក, ដង្ហើមខ្លី ឬពិបាកដកដង្ហើម, ញាក់ញ័រម្តងហើយម្តងទៀត, ឈឺសាច់ដុំ, ឈឺក្បាល, ឈឺបំពង់ក, បាត់បង់រសជាតិ ឬក្លិនថ្មី, រមួល ឬក្អួតចង្អោ, រាគរូស, តឹងច្រមុះ ឬហៀរសំបោរ)។
- ❑ ធានាថាពួកគេពាក់គំរបមុខក្រណាត់ ឬម៉ាង់វះកាត់ ប្រសិនបើពួកគេមានអាយុលើសពី ២ ឆ្នាំ ហើយមិនមានបញ្ហាក្នុងការពាក់ ឬដោះរបាំងមុខចេញ ឬមានបញ្ហាដកដង្ហើមនៅពេលដែលពាក់របាំងមុខលើ។
- ❑ អ្នកបោះជំរុំ ឬបុគ្គលិកដែលបង្ហាញរោគសញ្ញានានា គួរតែស្ថិតនៅក្នុងបន្ទប់ដាច់ឆ្ងាយពីគេរហូតដល់គេអាចដឹកទៅផ្ទះបាន ឬទៅកាន់កន្លែងថែទាំសុខភាព, អោយបានកាន់តែឆាប់ តាមដែលអាចអនុវត្តទៅបាន។
- ❑ បង្កើតនីតិវិធីសម្រាប់ដឹកអ្នកជម្ងឺទៅផ្ទះឬទៅមណ្ឌលសុខភាពដោយសុវត្ថិភាពតាមតម្រូវការ។ ទូរស័ព្ទទៅ ៩-១-១ ដោយគ្មានការពន្យាពេលប្រសិនបើបុគ្គលម្នាក់ៗមានការឈឺចាប់ឬសម្ពាធជាប់ៗគ្នាក្នុងទ្រូងការភាន់ច្រលំឬបបូរមាត់ឬផ្ទៃមុខ។
- ❑ សូមណែនាំសមាជិកបុគ្គលិក និងអ្នកបោះជំរុំដែលឈឺ កុំអោយវិលត្រឡប់មកវិញ រហូតដល់ពួកគេបានបំពេញតាមលក្ខណៈវិនិច្ឆ័យរបស់ CDC ដើម្បីបញ្ឈប់ភាពឯកោនៅផ្ទះ, រួមមាន ២៤ ម៉ោង ឬ ១ ថ្ងៃ ដោយគ្មានគ្រុនក្តៅ, រោគសញ្ញាមានភាព ប្រសើរឡើង និង ១០ ថ្ងៃ ចាប់តាំងពីរោគសញ្ញាបានលេចចេញមកជាលើកដំបូង។
- ❑ ណែនាំអោយទំនាក់ទំនងទៅបុគ្គលដែលមានជម្ងឺ ស្នាក់នៅផ្ទះរយៈពេល ១៤ ថ្ងៃ បន្ទាប់ពីការទំនាក់ទំនងចុងក្រោយ និងតាមដានរោគសញ្ញាជំងឺ COVID-19 និងអនុវត្តតាមបទបញ្ជារបស់មន្ត្រីសុខភាពទីក្រុងឡុងប៊ិច សំរាប់ការដាក់ខ្លួនអោយនៅឯកោ និង ការដាក់ខ្លួនអោយនៅឃ្លាតឆ្ងាយពីអ្នកដទៃ, ប្រសិនបើអាចធ្វើទៅបាន។
- ❑ Advise contacts to the ill individual to stay at home for 14 days after the last contact and monitor for symptoms of COVID-19 and to follow the Long Beach Health Officer Orders for self-isolation and quarantine, if applicable.

- ❑ ក្នុងករណីដែលមានករណីចំនួន ៣ ឬច្រើនជាងនេះ ត្រូវបានរកឃើញថាមានករណីវិជ្ជមានជំងឺ COVID-19 នៅក្នុង រយៈពេល ១៤ ថ្ងៃ ប្រតិបត្តិករគួរតែរាយការណ៍ពីចង្កោមហេតុការណ៍នេះ ទៅមន្ទីរសុខាភិបាល និងសេវាមនុស្ស នៃទីក្រុងឡុងប៊ិច តាមលេខ ៥៦២-៥៧០-INFO, និងជូនដំណឹងដល់បុគ្គលិក និងក្រុមគ្រួសារទាំងអស់ជាបន្ទាន់ ខណៈពេលដែលរក្សាការសម្ងាត់ ដូចដែលបានកំណត់ដោយច្បាប់រដ្ឋ និងសហព័ន្ធ។
- ❑ បិទកន្លែងដែលប្រើដោយមនុស្សឈឺ ហើយកុំប្រើមុនពេលសម្អាត និងរំងាប់មេរោគ។ ប្រសិនបើអាចធ្វើទៅបាន, សូមរង់ចាំ ២៤ ម៉ោង ឬយូរតាមដែលអាចធ្វើទៅបាន មុនពេលសម្អាត និងរំងាប់មេរោគតំបន់នោះ។
- ❑ ធានាឱ្យបាននូវការប្រើប្រាស់ថ្នាំសម្លាប់មេរោគដោយសុវត្ថិភាព និងត្រឹមត្រូវ ដោយប្រើឧបករណ៍ការពារផ្ទាល់ខ្លួន និងខ្យល់ចេញចូលដែលត្រូវបានណែនាំសម្រាប់សម្អាត។ សូមទុកដាក់នូវផលិតផលសំអាត និងផលិតផលសំឡាប់ មេរោគ ឱ្យឆ្ងាយពីកុមារ។
- ❑ នៅក្នុងការពិគ្រោះយោបល់ជាមួយមន្ទីរសុខាភិបាលសាធារណៈក្នុងតំបន់, មន្ត្រីជំរុំសមរម្យអាចពិចារណា ប្រសិនបើការបិទត្រូវបានធានា និងរយៈពេល ដែលផ្អែកលើកម្រិតហានិភ័យ នៅក្នុងសហគមន៍ជាក់លាក់។

**កំរឹតក្នុងការចែករំលែក**

- ❑ ទុករបស់របរផ្ទាល់ខ្លួនទាំងឡាយរបស់អ្នកបោះជំរុំ អោយនៅដាច់ដោយឡែកពីគ្នា និងដាក់ក្នុងធុងផ្ទុកឥវ៉ាន់, គូប ឬកន្លែងនីមួយៗដែលមានដាក់ស្លាកសញ្ញាបុគ្គលនិមួយៗ។ ធានាថា របស់របរត្រូវបានយកទៅផ្ទះរាល់ថ្ងៃដើម្បីធ្វើការសំអាត និងរំងាប់មេរោគ។
- ❑ ធានាការផ្គត់ផ្គង់អោយបានគ្រប់គ្រាន់ ដើម្បីកាត់បន្ថយការចែករំលែកនូវសំភារៈដែលមានការប៉ះពាល់ខ្ពស់ (សំភារៈសិល្បៈ, ឧបករណ៍ ។ល។) ដល់កំរិតដែលអាចអនុវត្តបាន ឬកំណត់ការប្រើប្រាស់គ្រឿងបរិក្ខារ និងសំភារៈដល់កុមារមួយក្រុម ក្នុងពេលតែមួយ ហើយធ្វើការសំអាត និងរំងាប់មេរោគរវាងការប្រើប្រាស់។
- ❑ ជៀសវាងការចែករំលែកឧបករណ៍អេឡិចត្រូនិច, សម្លៀកបំពាក់, ប្រដាប់ប្រដាក្មេងលេង, សៀវភៅ, និងហ្គេមដ៏ទៃទៀត ឬជំនួយការរៀនតាមសូត្រ តាមដែលអាចអនុវត្តន៍បាន។

## F. វិធានការណ៍នានា ដែលទំនាក់ទំនងទៅកាន់សាធារណៈជន

រក្សាប្រព័ន្ធទំនាក់ទំនង ដែលអនុញ្ញាតិអោយ បុគ្គលិកនិងភ្ញៀវទេសចរណ៍ រាយការណ៍រោគសញ្ញាដោយខ្លួនឯង និងទទួលបានការជូនដំណឹងភ្លាមៗនៃការប្រឈម និងការទៅជិត, ខណៈពេលដែលរក្សាបាននូវការសម្ងាត់។

- ❑ ច្បាប់ចតចំលងពិធីការនេះ ត្រូវបានបិទផ្សាយនៅតាមច្រកចូលសាធារណៈ ចូលទៅកាន់កន្លែងនានា។
- ❑ ស្លាកសញ្ញានៅច្រកចូល ជូនដំណឹងអតិថិជនអំពីដែនកំណត់ ឬកំរឹតនៃការកាន់កាប់។
- ❑ សញ្ញា ត្រូវបានដាក់បង្ហាញនៅតាមច្រកចូលនានា, តំបន់រងចាំ, និងនៅតាមទីធ្លាខាងក្រៅ ដើម្បីរំលឹក មនុស្សអោយមានការនៅឃ្លាតឆ្ងាយរាងកាយពីគ្នា និងប្រើប្រាស់គម្របមុខ នៅគ្រប់ឱកាសទាំងអស់។ បុគ្គលិកឧទ្ទិស ត្រូវបានប្រើដើម្បីដឹកនាំភ្ញៀវនៅតំបន់ដែលមានចរាចរណ៍ខ្ពស់ និងតំបន់កកស្ទះ ដើម្បីបញ្ចៀសការជួបជុំប្រមូលផ្តុំគ្នា។

- ❑ សញ្ញាសម្គាល់ត្រូវបានបិទផ្សាយដែលណែនាំអ្នកទេសចរណ៍ថា ពួកគេគួរតែស្នាក់នៅផ្ទះប្រសិនបើឈឺដោយរោគសញ្ញាផ្លូវដង្ហើមនានា។
- ❑ អនឡាញអៅឡែតនៃទីកន្លែង (គេហទំព័រ, ប្រព័ន្ធផ្សព្វផ្សាយសង្គម ។ល។) ផ្តល់នូវព័ត៌មានច្បាស់លាស់អំពី អំពីម៉ោងពេលហាង, តម្រូវការប្រើប្រាស់គម្របមុខ, ការកាន់កាប់ដែលមានកំណត់/កំរឹត, គោលនយោបាយទាក់ទងនឹងការលក់សំបុត្រ, ការចូល, ការបញ្ជាទិញជាមុន, ការទូទាត់ជាមុន, ការមកទទួល និង/ឬការចែកចាយ/បញ្ជូនអោយ និងបញ្ហាពាក់ព័ន្ធផ្សេងទៀត។

## G. វិធានការណ៍នានា ដែលធានានូវការទទួលបានសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

- ❑ សេវាកម្មនានាដែលមានសារៈសំខាន់សម្រាប់អ្នកបោះជំរុំ ត្រូវបានផ្តល់អាទិភាព។
- ❑ វិធានការណ៍នានា ត្រូវបានបង្កើតឡើង ដើម្បីធានានូវសេវាកម្មសម្រាប់អ្នកបោះជំរុំ ដែលមានកម្រិតនៃការចល័ត និង/ឬ មានហានិភ័យខ្ពស់នៅក្នុងទីធ្លាសាធារណៈ។

**វិធានការណ៍បន្ថែមណាមួយ ដែលមិនបានដាក់បញ្ចូលខាងលើ គួរតែត្រូវបានដាក់រាយនៅលើទំព័រដាច់ដោយឡែក , ដែលអាជីវកម្ម គួរតែភ្ជាប់ជាមួយនឹងឯកសារនេះ។**

**អ្នកអាចទាក់ទងមនុស្សខាងក្រោមនេះ បើសិនជាអ្នកមានសំណួរ ឬយោបល់នានា អំពីពិធីការនេះ:**

ឈ្មោះទំនាក់ទំនងជំរុំ: ______________________

លេខទូរស័ព្ទ: ______________________

កាលបរិច្ឆេទកែប្រែចុងក្រោយ: ______________________

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**